ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០២៧សហវ.......

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមការងារចំពោះកិច្ច រៀបចំគោលនយោបាយថវិកា ហិរញ្ញប្បទាន និង ជំនួយសង្គម ដើម្បីគ្រប់គ្រងការប្រយុទ្ធនឹងជំងឺ កូវីដ-១៩

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្ដីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្ដីពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)
- យោងតាមតម្រូវការចាំបាច់របស់ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ១.**

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ច រៀបចំគោលនយោបាយថវិកា ហិរញ្ញប្បទាន និង ជំនួយសង្គម ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២. លោកជំទាវ **យក់ សម្បត្តិ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. ឯកឧត្តម **ចាន់ សុធី** | អនុរដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៤. ឯកឧត្តម **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការ កសហវ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គសហ) | អនុប្រធាន |
| ៥. ឯកឧត្តម **ឆួន ថាវរៈ** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៦. ឯកឧត្តម **សំហេង បូរស** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧. ឯកឧត្តម **ហេង សួរ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. ឯកឧត្តម **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ៩. ឯកឧត្តម **វង្ស ប៊ុនឥន្រ្ទាទុង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ កសហវ | សមាជិក |
| ១០. ឯកឧត្តម **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ១១. ឯកឧត្តម **មុី វ៉ាន់** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ កសហវ | សមាជិក |
| ១២. ឯកឧត្តម **ទេព តិយ៉ាវិរុទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ កសហវ | សមាជិក |
| ១៣. ឯកឧត្តម **ម៉ែន ធីរុត្ថ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល កសហវ | សមាជិក |

| | | |
|---|---|---|
| ១៤. ឯកឧត្តម **ចន ណារិទ្ធ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម កសហវ | សមាជិក |
| ១៥. ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គសហ | សមាជិក |
| ១៦. លោក **ម៉ក់ ទិចិត្រសក្ដដា** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គសហ | សមាជិក |
| ១៧. លោក **ចន្ថា ម៉េងលី** | សេដ្ឋវិទូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានគោលនយោបាយ កសហវ | សមាជិក |

**ប្រការ២.**

ក្រុមការងារចំពោះកិច្ចនេះ មានភារកិច្ចដូចខាងក្រោម÷

- សិក្សា និងកំណត់ទំហំតម្រូវការថវិកាជាក់ស្ដែង ស្របតាមការចាំបាច់សម្រាប់គ្រប់គ្រងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយឈរលើគោលការណ៍អាទិភាពចំនួន ០៣÷ (១) ការប្រយុទ្ធនឹងជំងឺកូវីដ-១៩, (២) ការរក្សាលំនឹងជីវភាពប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត និង(៣) ការស្រោចស្រង់ និងរក្សាលំនឹងអាជីវកម្ម-ធុរកិច្ច,
- បន្តពិនិត្យ និងផ្ដល់អនុសាសន៍ពាក់ព័ន្ធនឹងការធ្វើវិចារណកម្មចំណាយថវិកា និងការធ្វើវិភាជន៍ថវិកាឡើងវិញ ដើម្បីបំពេញតម្រូវការថវិកាសម្រាប់គ្រប់គ្រងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ផង និងដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចផង,
- បន្តធ្វើការកៀរគរឱ្យបានជាអតិបរមានូវ ធនធានហិរញ្ញប្បទានពីក្រៅប្រទេស ដូចជា មូលនិធិទ្រទ្រង់ថវិកា (Budget support) និងជំនួយបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី,
- សិក្សា រៀបចំ និង ពិនិត្យលទ្ធភាពនូវជម្រើសក្នុងការខ្ចីឥណទានពីធនាគារពាណិជ្ជ និងធនាគារជាតិនៃកម្ពុជា ក៏ដូចជា ការកៀរគរហិរញ្ញប្បទាន ពីវិស័យឯកជនតាមរយៈការបោះផ្សាយសញ្ញាបណ្ណរដ្ឋ,
- សិក្សា និងវាយតម្លៃអំពីធនធានជាក់ស្ដែងដែលមាន និងការត្រៀមបម្រុងសម្រាប់ពេលអនាគត ពិសេសពិនិត្យលទ្ធភាពក្នុងការប្រមូលចំណូលគ្រប់ប្រភេទ ទាំងចំណូលពន្ធដារ, ចំណូលពន្ធគយ និងចំណូលមិនមែនពន្ធផ្សេងៗទៀត,
- រៀបចំគោលនយោបាយ និងវិធានការចាំបាច់នានា ដើម្បីជួយសម្រាលផលប៉ះពាល់ដល់ធុរជន និងប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត ដើម្បីរក្សាស្ថិរភាព និងលំនឹងនៃធុរកិច្ចនិងជីវភាព ដោយផ្ដល់អាទិភាពខ្ពស់ដល់កម្មករ-និយោជិត និងប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត ដែលអាចនឹងបាត់បង់ការងារ, អាជីវកម្ម និងមុខរបររបស់ខ្លួន,

- សិក្សា និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការធ្វើអត្តសញ្ញាណកម្មក្រុមជនដែលរងគ្រោះ ដែលអាចរួមមានដូចជា÷ ប្រជាពលរដ្ឋដែលប្រើប្រាស់ ប្រព័ន្ធប័ណ្ណក្រីក្រប្រភេទ ១ និង ២ និងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) ព្រមទាំង កម្មករ-និយោជិតធ្វើការនៅក្រៅប្រព័ន្ធ និងប្រជាពលរដ្ឋក្រីក្រផ្សេងៗទៀត,
- សិក្សា និងរៀបចំយន្តការនៃការឧបត្ថម្ភជាសៀវ ដោយគិតគូរពីទំហំ, ប្រភេទម្ហូបអាហារ និងគោលដៅជាដើម ដើម្បីដោះស្រាយការលំបាក និងតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ក៏ដូចជាដើម្បីរក្សាសន្តិ-សុខ និងសណ្តាប់ធ្នាប់សង្គម,
- សិក្សា និងរៀបចំយន្តការអនុវត្តប្រកបដោយសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយ ដើម្បីតម្រង់ការផ្តល់ជំនួយសង្គមឱ្យចំទិសដៅក្នុងការដោះស្រាយបញ្ហាចំពោះមុខឱ្យមានប្រសិទ្ធភាពខ្ពស់,
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៣.**

ក្រុមការងារចំពោះកិច្ចអាចប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីជួយសម្រួលការងារតាមការចាំបាច់។

**ប្រការ៤.**

សមាសភាពនៃក្រុមការងារចំពោះកិច្ចនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

ក្រុមការងារចំពោះកិច្ចនេះ មានសិទ្ធិអញ្ជើញភាគីពាក់ព័ន្ធ និងវិស័យឯកជន ចូលរួមប្រជុំតាមការចាំបាច់ ។

ក្រុមការងារចំពោះកិច្ចនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៥.**

ក្រុមការងារចំពោះកិច្ចនេះ អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ។

**ប្រការ៦.**

តួនាទី និងភារកិច្ចរបស់ក្រុមការងារចំពោះកិច្ច ដែលត្រូវបានកំណត់ក្នុងសេចក្តីសម្រេចនេះ ត្រូវមានអានុភាពអនុវត្តរហូតដល់ការប្រយុទ្ធនឹងជំងឺកូវីដ១៩ ត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ៧.**

សមាសភាពក្រុមការងារចំពោះកិច្ចទាំងអស់មកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល ក្រសួងផែនការ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, អគ្គលេខាធិការដ្ឋាននៃ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការ-

ដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ថ្ងៃសុក្រ ១១ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ